**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ..៦៣២..សហវ..អលសា

រាជធានីភ្នំពេញ, ថ្ងៃទី០៣ខែកុម្ភៈឆ្នាំ២០១៧

**ជម្រាបជូន**

**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា**

**ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា**

**កម្មវត្ថុ៖** ករណីសំណើសុំអនុម័តលទ្ធផលចរចាថ្លៃ និងចុះកិច្ចសន្យាជាមួយក្រុមហ៊ុន E.M Construction លើថ្លៃធ្វើកាណាល់ដាក់កាប 22KV Power Cable ជា Concrete Cable Trench មានបណ្ដោយប្រវែង 60m ទទឹងប្រវែង 3.2m ជម្រៅប្រវែង 2m និងកម្រាស់ 0.15m និងការងារផ្សេងៗទៀត នៅអនុស្ថានីយ៍អគ្គិសនីទី1 និងទី3 ។

**យោង** ៖ - លិខិតលេខ ១១៥៤១ សហវ.អលសា ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- កំណត់ហេតុចរចាថ្លៃ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់អគ្គិសនីកម្ពុជា
- លិខិតលេខ ០២២៩ លស.អក.លក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៧ របស់អគ្គិសនីកម្ពុជា ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមប្រតិភូមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុយល់ព្រមតាមសំណើរបស់អគ្គិសនីកម្ពុជា ប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន E.M Construction លើថ្លៃធ្វើកាណាល់ដាក់កាប 22KV Power Cable ជា Concrete Cable Trench មានបណ្ដោយប្រវែង 60m ទទឹងប្រវែង 3.2m ជម្រៅប្រវែង 2m និងកម្រាស់ 0.15m និងការងារផ្សេងៗទៀត នៅអនុស្ថានីយ៍អគ្គិសនីទី1 និងទី3 ក្នុងតម្លៃសរុបចំនួន ១៦៧ ៥០០.០០ USD (មួយរយហុកសិបប្រាំពីរពាន់ ប្រាំរយដុល្លារអាមេរិកគត់) ជាតម្លៃកិច្ចសន្យា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមប្រតិភូមេត្តាជ្រាប និងមានវិធានការអនុវត្តបន្តឱ្យសមស្របតាមនីតិវិធីលទ្ធកម្មសាធារណៈតាមការគួរ ។

សូមឯកឧត្តមប្រតិភូទទួលនូវការរាប់អានពីខ្ញុំ ។

ជ.-ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុរដ្ឋលេខាធិការ

ពៅ ង សម្បត្តិ

**ចម្លងជូន៖**

- -អគ្គនាយកដ្ឋានពន្ធដារ
- -ក្រុមហ៊ុន E.M Construction
- -ឯកសារ-កាលប្បវត្តិ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.

ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៦ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 666 Fax : 855-23-427 798